ឧត្តមសេនីយ៍មេបញ្ជាការនៃកងទ័ពអាកាស ខ្មែរ សូ សាតូ បានថ្លែងចំពោះមុខកូនទាហានរបស់ខ្លួនក្នុងពិធីជួបជុំរម្លឹកខួបឆ្នាំទី35 ដែលជាការជួបជុំធំបំផុតមួយឱ្យដឹងថា ពេលវេលារសាត់ទៅដែលស្ទើរតែមិនជឿគឺ35ឆ្នាំកន្លងទៅហើយ ដែលយើងបានឃ្លាតឆ្ងាយពីគ្នាដែលគួរឱ្យរំជួលចិត្តជាទីបំផុត ។ អនុស្សាវរីយ៍កាលពីនៅក្នុងកងទ័ពអាកាសបានស្ថិតនៅក្នុងអារម្មណ៍យើងជានិច្ច មិនអាចរលុបបានមួយវិនាទីណាឡើយ អ្វីៗដែលកន្លងទៅក្លាយទៅជាប្រវត្តិសាស្ត្ររួចទៅហើយ ប៉ុន្តែយើងគ្រាន់តែចង់រក្សាទុកនូវភស្តុតាង និងសក្ខីកម្មជូនខេមរជនជំនាន់ក្រោយបន្តវេនជាទ័ពអាកាសឱ្យមាន ប្រសិទ្ធភាពអាចការពារដែនអាកាសខ្មែរយើងបាន ដើម្បីរក្សាការពារមាតុភូមិរបស់យើងបន្តទៅទៀត" ។

ឧត្តមសេនីយ៍ សូ សាតូ បានថ្លែងបន្តទៀតថា ឆ្លៀតឱកាសនេះខ្ញុំសូមលំឱនកាយគោរពចំពោះវីរភាពរបស់មិត្តរួមអាវុធដែលបានបូជាជីវិតក្នុងសមរភូមិក្តី ក្នុងរបបខ្មែរក្រហមក្តី និងនៅកន្លែងផ្សេងទៀតក្តី ហើយអំពាវនាវឱ្យអស់លោកទាំងអស់គ្នា ជាសមាជិកទ័ពអាកាសខ្មែរ សូមរក្សាឱ្យបាននូវមូលដ្ឋានគ្រឹះនៃទ័ពអាកាស គឺបន្តការស្រឡាញ់គ្នា រាប់អានគ្នាសង្គ្រោះគ្នាទៅវិញទៅមកក្នុងឋានៈជាសមាជិកគ្រួសារតែមួយរហូតដល់អវសាន្តនៃជីវិត ។



ចំណែកលោកវរសេនីយ៍ឯក នរោត្តម បាលី បានថ្លែងក្នុងពិធីនោះថា ជាងកន្លះសតវត្សរ៍មក ហើយដែលទ័ពអាកាសខ្មែរបានចាប់បដិសន្ធិ ហើយរីកដុះដាលក្លាយទៅជាទ័ពអាកាសមួយ ដែលមានហេដ្ឋានរចនាសម្ព័ន្ធយន្តហោះគ្រប់ប្រភេទ និងមានបុគ្គលិកបម្រើការដែលមានជំនាញ និងវិជ្ជាជីវៈខ្ពស់ ពោល គឺទ័ពអាកាសមួយដែលអាចការពារជាតិ បូរណភាពទឹកដី មាតុភូមិ និងប្រជាពលរដ្ឋដែលគួរឱ្យមានមោទនភាពជាទីបំផុត ។ ទ័ពអាកាសខ្មែរ គឺបានប្តេជ្ញាចិត្តលះបង់ជីវិតក្នុងន័យបម្រើជាតិមាតុភូមិយ៉ាងប្តូរផ្តាច់ជាទីបំផុត ។

រីឯអ្នកអង្គម្ចាស់ Rathary Dimang Sisowath បានថ្លែងថា "កាលពីសម័យដែលយើងចាប់ផ្តើមចូលខ្លួនបម្រើកងទ័ពអាកាសខ្មែរយើង មានមាឌធំ ខ្ពស់សង្ហារ នាំម៉ូដវ៉ែនតា Ray Ban និងនាឡិកា Omega


អ្នកអង្គម្ចាស់ Rathary Dimang Sisowath

មុខធំៗចូលទៅក្នុងប្រទេសកម្ពុជា យើងហោះហើរសម្តែងឫទ្ធិក្នុងអាកាសលើបក្សាស្លាបដែក ឥឡូវនេះ សង្ហារតែខាងក្រៅទេ Ray Ban ក្លាយទៅជា Ray Ban បក្សាស្លាបដែកក្លាយទៅជាដំបងដែកសម្រាប់ទប់ខ្លួនទៅវិញ ។

ក្នុងរបបសាធារណៈរដ្ឋខ្មែរ កងទ័ពអាកាសខ្មែរមានចំនួនជាង9000នាក់ ជាមួយយន្តហោះគ្រប់ប្រភេទសរុប 248គ្រឿងសម្រាប់ការហោះហ្វឹកហ្វឺន ការទំនាក់ទំនង និងដឹកនាំកងប្រដេញប្រយុទ្ធយន្តហោះកងសង្កេតការណ៍ និងកងឧទ្ធម្ភាគចក្រ ។

នៅក្នុងសមរភូមិសង្គ្រាមនាអតីតកាលនោះ គេប៉ាន់ស្មានថា មានទាហានទ័ពអាកាសដែលបើកយន្តហោះប្រយុទ្ធចំនួនជាង300នាក់បានស្លាប់បាត់បង់ជីវិត ដើម្បីរក្សាការពារមាតុភូមិជាទីស្រឡាញ់របស់ពួកគេ ។

អំពីដើមកំណើតនៃកងយោធពលអាកាសខ្មែរ រហូតមកដល់សម័យសង្គ្រាមលោកលើកទី2 ទៅហើយ ពុំមានកុលបុត្រខ្មែរណាម្នាក់បានបើកបរយន្តហោះទេ ។ ទើបតែក្នុងឆ្នាំ 1939 បានព្រះអង្គម្ចាស់ Sisowath Moni pong បាន ចេញពីសាលាអាកាសយានិកនៅ Provence ប្រទេសបារាំង និងព្រះអង្គម្ចាស់ Norodom Songdeth បានចូលរួមក្នុងបេសកកម្មទម្លាក់គ្រាប់បែកក្នុងសង្គ្រាមលោកលើកទី2រវាងប្រទេសបារាំង និងប្រទេសអ៊ីតាលី ។

ក្រោយសម័យឯករាជ្យបារាំងបានប្រគល់អំណាចកងទ័ពមកឱ្យខ្មែរកាន់កាប់ ទើបព្រះករុណា នរោត្តម សីហនុ តាមព្រះរាជក្រឹត្យមួយក្នុងឆ្នាំ 1954 បានបង្កើតកងយោធពលអាកាសខ្មែរ ហើយបានតែងតាំងលោក Ngo Hou ដែលជា វេជ្ជបណ្ឌិតក្នុងឋានន្តរសក្តិជាវរសេនីយ៍ទោ និងលោក Keu Pau An ដែលជាអធិការក្រសួងរក្សាប្រមាញ់ និងទេសាទ ក្នុងឋានន្តរសក្តិជាអនុសេនីយ៍ឯកឱ្យរៀបចំកងទ័ពអាកាសខ្មែរក្រោមការណែនាំរបស់បេសកកម្មយោធាបារាំងប្រចាំប្រទេសកម្ពុជា ។ កងទ័ពអាកាសខ្មែរជំនាន់ទី1 បានចាប់កំណើតនៅឆ្នាំ1954 និងជំនាន់ចុងក្រោយទី11បានចាប់កំណើតនៅឆ្នាំ1974 ៕

# ទ័ពអាកាសខ្មែរ
# Khmer Air Force

•••ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ សមាជិកទ័ពអាកាសខ្មែរមួយចំនួនបានភៀសខ្លួនចេញពីប្រទេសនៅថ្ងៃចុងក្រោយនៃសង្គ្រាមក្តៅកាន់ប្រទេសសៀម រួចបន្តទៅកាន់ប្រទេសទី៣ មានសហរដ្ឋអាមេរិក និងប្រទេសបារាំងជាដើម ភាគច្រើននៅសហរដ្ឋអាមេរិក ហើយភាគច្រើនទៅទៀត គឺត្រង់ភាគខាងត្បូងនៃរដ្ឋកាលីហ្វ័រនីញ៉ានេះឯង ។ នេះជាលើកទី១ហើយដែលសមាជិកទ័ពអាកាសខ្មែរធ្វើពិធីជួបជុំគ្នាជាទ្រង់ទ្រាយធំ ដែលមិនធ្លាប់មានតាំងពី៣៥ ឆ្នាំកន្លងមកហើយ។ ក្នុងឱកាសនេះដែរ មានសមាជិកទ័ពអាកាសពីប្រទេសបារាំងមួយចំនួន ជាពិសេស លោកអតីតឧត្តមសេនីយ៍ អគ្គមេបញ្ជាការទ័ពអាកាសខ្មែរ សូ សាតូ ក៏បានអញ្ជើញមកចូលរួមជាកិត្តិយសក្នុងពិធីនេះដែរ ។ នេះប្រាកដជាការជួបជុំមួយប្រកបដោយមនោសញ្ចេតនារំភើបរីករាយរកអ្វីមកប្រៀបពុំបានឡើយ ។

សៀវភៅទ័ពអាកាសខ្មែរមានបរិយាយពីប្រវត្តិនៃការកកើតទ័ពអាកាសចរខេមរភូមិន្ទក្នុងសម័យរាជានិយម រហូតមកដល់ទ័ពអាកាសខ្មែរក្នុងសម័យសាធារណរដ្ឋខ្មែរ។ សៀវភៅនេះ នៅមានរៀបរាប់ពីនាយទាហានជំនាន់ទី១រហូត ដល់ជំនាន់ទី១១ ហើយ និងរៀបរាប់ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រទាំងឡាយ ដែលទាក់ទងទៅនឹងទ័ពអាកាសខ្មែរផងដែរ ។

សូមរង់ចាំអានប្រវត្តិទ័ពអាកាសខ្មែរពីឆ្នាំ១៩៧៥ ដែលមានចេញផ្សាយក្នុងពេលឆាប់ៗនេះ។

# ការបដិសន្ធិ និងប្រវត្តិនៃអាកាសចរខេមរភូមិន្ទ


ព្រះអង្គម្ចាស់ ស៊ី សុវត្ថិមុនីពង្ស ជាអាកាសយានិកលើកទី១ នៃប្រវត្តិសាស្ត្រខ្មែរក្នុងឆ្នាំ១៩៣៩


ព្រះអង្គម្ចាស់ ស៊ី សុវត្ថិមុនីពង្ស ជាអាកាសយានិកនៅក្នុងទ័ពអាកាសបារាំងក្នុងសហព័ន្ធឥណ្ឌូចិនឆ្នាំ១៩៥០ ព្រះអង្គស្ថិតនៅក្នុងកងសង្កេតការទទួលបន្ទុក ឥណ្ឌូចិន មានកម្ពុជាផងដែរ

## ការចាប់ផ្តើម

នៅមុន និងក្នុងរយៈពេលសង្គ្រាមលោកលើកទី២ ខេមរជនតិចណាស់ដែលមានវាសនាជាអ្នកហោះហើរនៅលើបក្សីស្លាបដែក។ ដោយសារជំនាន់នោះ ប្រទេសខ្មែរយើងស្ថិតនៅក្នុងសហព័ន្ធបារាំង អាកាសយានិកខ្មែរត្រូវហោះនៅក្នុងទ័ពអាកាសបារាំង ។

សូមរំឭកថា នៅឆ្នាំ១៩៣៨ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីពង្ស បានទទួលការហ្វឹកហ្វឺនក្នុងទ័ពអាកាសបារាំង នៅ Salon de Provence ។ នៅក្នុងសង្គ្រាមលោកលើកទី២ អ្នកអង្គម្ចាស់ សុន ដេត ក៏ជាអាកាសយានិកនៅក្នុងទ័ពអាកាសបារាំង ហើយលោកហោះយន្តហោះ B-26 Marauder រួចបានបំពេញបេសកកម្មនៅប្រទេសអ៊ីតាលីទៀតផង។

អស់រយៈពេលជាច្រើនឆ្នាំក្រោយមកនៅភ្នំពេញមានក្លឹបហោះហើរឯកជនមួយហើយ នៅពេលនោះមាននាយទាហានខ្លះបានទទួលសញ្ញាប័ត្រហោះហើរពីក្លឹបនេះផងដែរ។

នៅខែមេសា ឆ្នាំ១៩៥៤ ព្រះរាជក្រឹត្យមួយបានប្រកាសបង្កើតទ័ពអាកាសខ្មែរ ដោយប្រសិទ្ធិនាមថា "**អាកាសចរខេមរភូមិន្ទ** Aviation Royale Khmere" ហើយសមាជិកក្លឹបហោះហើរភ្នំពេញ (Phnom Penh Flying Club) បានបញ្ចូលមកជាអ្នកដឹកនាំទ័ពអាកាសនេះ។ **លោកវេជ្ជបណ្ឌិត ង៉ោ ហ៊ូ** ជាអាកាសយានិកមួយរូបក្នុងក្លឹបនេះ បានទទួលឋានៈជាមេបញ្ជាការអាកាសចរខេមរភូមិន្ទ ហើយមានឋានន្តរស័ក្តិជាវរសេនីយ៍ទោ និង**លោក តឺ ប៉ូអាន** ជាមេព្រៃក្លាយជាមេបញ្ជាការរង ហើយមានឋានន្តរស័ក្តិជាអនុសេនីយ៍ឯក។ បុគ្គលិកជាច្រើនរូបទៀតពីកងទ័ពថ្មើរជើងបានផ្ទេរឱ្យមកបំរើទ័ពអាកាស ហើយកាលនោះមានទីប្រឹក្សារបស់ទ័ពអាកាសបារាំង ដែលមានលោកវរសេនីយ៍ត្រី De Salabery ជាមេបញ្ជាការ។ ក្រោយមកទៀត ទីប្រឹក្សាទ័ពអាកាសបារាំងបានបើកវគ្គសិក្សាហ្វឹកហ្វឺនអាកាសយានិកខ្មែរ ដែលបង្ហាត់ដោយគ្រូបារាំងជាច្រើននាក់ ដូចជា André Bellouard ជាដើម។



(សូមអាន André Bellouard note និងព័ត៌មានច្រើនទៀតនៅ

**Website www.khmerairforce.com**

# អាថ៌កំបាំង និងសិល្បៈនៃជីវិត
# SECRET AND ART OF LIVING



(តមកពីលេខមុន)

រៀបរៀងដោយ
លោក ម៉ៅ ច័ន្ទសំណុំ

•••ឥឡូវនេះ យើងចូលទៅក្នុងបន្តិចពិនិត្យពិភពនៃចិត្តមនុស្សម្តងមើល ។ តើខ្ញុំជាចិត្តដែលកំពុងតែគិត កំពុងតែមានចិត្តរជើបរំជួលឬ? ពីមុនខ្ញុំតែងគិតថា ពិភពចិត្ត អារម្មណ៍ ការគិត កំហឹង ការទឹកឃើញ ។ល។ ជាតួរបស់ខ្ញុំ ជាសកម្មភាពរបស់ខ្ញុំ។ ឆ្លងតាមការពិចារណាលើកុងស្យនិសពេលដឹងខ្លួន Waking state និងកុងស្យនិសពេលយប់ សប្តិ Dreaming state ខ្ញុំមើលឃើញថា ពិភពផ្លូវចិត្តនេះពុំមែនខ្ញុំទេ។ ការគិត អារម្មណ៍ ប្រតិកម្ម មនោសញ្ចេតនា និន្នាការ ។ល។ ដែលកំពុងតែប្រព្រឹត្តទៅក្នុងចិត្តខ្ញុំនេះ **គឺជាការឆ្លើយឆ្លង ឬជះត្រឡប់ទៅមកជាស្វ័យប្រវត្តិ រវាងប្រអប់ម៉េម័រី និងពិភពខាងក្រៅខ្លួនប៉ុណ្ណោះ ។** ឧទាហរណ៍ : ខ្ញុំកំពុងអង្គុយ ស្រាប់តែឮសូរសម្លេងចម្លែកពីក្រៅផ្ទះមក សម្លេងពីក្នុងខ្លួនប្រាប់ថា មានហេតុអ្វីកើតឡើងហើយ ចូរចេញទៅមើល ! ខ្ញុំស្ទុះចេញទៅភ្លាម ឃើញឡានប៉ះគ្នា ។ សម្លេងមួយទៀតពីក្នុងមកថា ឡានរបស់នរណា ជារបស់កូនអញទេឬ? ។ល ។និង ។ល ។ បើអ្នកទៅមើលឡាន ការរកសោរដើរឆ្ពោះទៅឡាន ចូលអង្គុយ មូលសោរឡាន បើកភ្នែកឆ្វេងស្តាំ ដៃកាច់ចង្កូត ។ល ។ ហេតុការណ៍ និងសកម្មភាពទាំងអស់នេះ កើតឡើងជាស្វ័យប្រវត្តិ ជាទម្លាប់បញ្ជាពីក្នុងមក ។ ដូចខ្ញុំជំរាបជូនខាងលើស្រាប់ ពិភពផ្លូវចិត្តនេះ (ការគិត កំហឹង អារម្មណ៍) មានចរិត "ដែលមានទំនាក់ទំនង" វារណបទៅនឹងកុងស្យនិសបរិសុទ្ធនេះ វាពុំមានឯករាជ្យឈរម្នាក់ឯងបានឡើយ ។ ដូច្នេះ ពិភពផ្លូវចិត្តនេះ ពុំមែនជាខ្ញុំទេ ពុំមែនរបស់ខ្ញុំទេ ។ ចំណុចនេះហើយ ដែលព្រះពុទ្ធសាសនាលើកទ្រឹស្តីអនត្តា NO SELF (ដំណើរប្រព្រឹត្តទៅដោយឯកឯងនៃខន្ធ៥មានរូបកាយ វេទនា សញ្ញា សង្ខារ និងវិញ្ញាណ ដែលមានចរិកជាភាពទំនាក់ទំនង ) ។

បើកខ្ញុំពុំមែនជារូបកាយនេះ ជាចិត្តនេះ តើខ្ញុំជានរណា? តើធម្មជាតិពិតរបស់ខ្ញុំជានរណា? ឥឡូវនេះ យើងចូលជ្រៅមួយជាន់ទៀត ។

ដូចខ្ញុំបានរៀបរាប់ក្នុងការប្រៀបធៀប ទឹក ដី និងវត្ថុធ្វើអំពីដី ពន្លឺក្នុងម៉ាស៊ីនបញ្ចាំងកុន យើងបានឃើញថា កុងស្យនិសបរិសុទ្ធ ជាជីវិត life ជាសតិដឹង Awareness ជាអ្នកមើលពីក្នុងមក The observer From the inside out ជាមូលដ្ឋានគ្រឹះ ជាដើមចមនៃការករ Creation អ្វីៗទាំងអស់ក្នុងខ្លួនមនុស្សនេះ : ចលនាសរីរាង្គមានបេះដូង សួត ថ្លើម ប្រម៉ាត់ ម៉េម័រ លំហូរគំនិតប្រតិកម្ម ការរំជួលផ្លូវចិត្ត វេទនា អារម្មណ៍ ។ល។ ដំណើរប្រព្រឹត្តទៅនៃរូបកាយ និងពិភពចិត្តមនុស្សកើតចេញមកពីកុងស្យនិសបរិសុទ្ធ ហើយរលាយបាត់ក្នុងទីនោះវិញ សារចុះសារឡើង ។ ដូច្នេះ កុងស្យនិសបរិសុទ្ធជាធម្មជាតិពិតរបស់ខ្ញុំ ។ The puer consciousness is my true nature .

ការយល់ដោយប្រាជ្ញាថា កុងស្យនិសបរិសុទ្ធជាធម្មជាតិពិតរបស់ខ្ញុំ "ខ្ញុំពុំមែនជារូបកាយនេះទេ" ខ្ញុំពុំមែនជាចិត្តនេះទេ" ជាជំហានមួយដ៏ធំឆ្ពោះទៅរកការរួមរំដោះ និងសេរីភាព ។ គួរយើងយល់ដឹងមួយកំរិតទៀតក្នុងវិស័យប្រតិបត្តិ ផ្ទាល់តាមពិសោធផ្ទាល់ ។ មនុស្សមានលទ្ធភាពនឹងដាក់សតិ ឬតំរង់សតិ ឬប្រមូលផ្តុំសតិ Put the attention or focus the attention or concentrate the attention ទៅក្រៅខ្លួន ទៅលើរូបកាយ ទៅក្នុងចិត្ត ឬពិសេសទៅក្នុងកុងស្យនិសបរិសុទ្ធ។ យើងអាចដាក់សតិទៅលើសៀវភៅ ដើម្បីអានសៀវភៅ (ខាងក្រៅ) ។ ពេលណាយើងដើរទង្គិចប៉ះក្បាល ឬជើង សតិយើងនឹងបាញ់រកក្បាល ឬជើង(លើរូបកាយ) ។ ថ្លឹងថ្លែងស្រាវជ្រាវរកហេតុផល(លើផ្ទៃចិត្ត) ។ ពេលយើងខឹងមួរម៉ៅ សតិយើងបានស្រូបទាំងស្រុងទៅក្នុងកំហឹងមួរម៉ៅ ហើយលង់សតិនៅទីនោះ "បាត់សតិ" (លើការរំជើបរំជួលចិត្ត emotion) ។

អ្វីដែលខ្ញុំរៀបរាប់មកនេះ អ្នកពិតជាពិសោធដូចខ្ញុំដែរ ។ ប៉ុន្តែការតម្រង់សតិទៅតំបន់កុងស្យនិសបរិសុទ្ធ អ្នកពុំធ្លាប់ ហើយពុំដឹងជាធ្វើដូចម្តេចផង ។ ប្រហែលយូរៗម្តង សតិអ្នកធ្លាក់ដោយចៃដន្យ ឬចូលជ្រៅទៅក្នុង ហើយសំឡឹងមើលពីក្នុងមក As observer or to be aware ទទួលដឹងថា មានអ្វីកំពុងកើតមាននៅក្រៅខ្លួន លើរូបកាយ ក្នុងចិត្ត អារម្មណ៍ (ដឹងដោយពុំមានការជ្រៀតជ្រែកពីម៉េម័រី ឬពីការគិតដោយខួរក្បាល -Knowing without interfering from unconscious mind or menory) ពិសោធរបៀបនេះ គឺលោកអ្នកបានទៅដល់តំបន់កុងស្យនិសបរិសុទ្ធហើយ ។ ប៉ុន្តែលោកអ្នកពុំអាចវែកញែកឱ្យច្បាស់ដូចអ្នកសមាធិបានឡើយ ។ សូមកុំព្រួយ សូមបន្តអានអ្នកនឹងដឹងច្បាស់ពុំខានឡើយ ។

ពេលនេះអ្នកគ្រាន់តែដឹងថា មនុស្សមានសមត្ថភាពអាចប្រមូលសតិទៅតំបន់កុងស្យនិសបរិសុទ្ធបានពិតជាបាន ហើយអាចពិតជាអាច ។ នេះជាសមត្ថភាព ដែលមនុស្សគ្រប់រូបមានសិទ្ធិនឹងទទួលពីធម្មជាតិ យើងត្រូវទាមទារសិទ្ធិពីកំណើតនេះឱ្យបាន ។ ចាំបាច់អ្នកមានកិច្ចការត្រូវធ្វើ ត្រូវហាត់ ព្រោះសមត្ថភាពនេះ ពុំកើតឡើងឯកឯងឡើយ ។ ពេលណាអ្នកចេះរបៀបហើយ ចេះតិកនិចហើយ ចេះម៉េតូដហើយ អ្នកនឹងមានបន្ទប់ពីរក្នុងខ្លួន បន្ទប់មួយសម្រាប់ពិសោធពិភពខាងក្រៅ(គិតទទួលអារម្មណ៍) ហើយបន្ទប់មួយទៀត សម្រាប់សម្រាក ក្រេមជញ្ជក់សេរីភាព សុខសាន្ត សប្បាយរីករាយក្នុងអារម្មណ៍ សន្តិភាពក្នុងចិត្តប្រាជ្ញាសាកល (ដែលជាសិទ្ធិពីកំណើត Birth Right) ។ល ។ (តទៅលេខក្រោយ)

New World Travel II
ញូវវល្ដត្រាវែលធូ

Specialized in Selling Flight Tickets
For National and International

ជំនាញខាងលក់សំបុត្រយន្តហោះសំរាប់ក្នុងប្រទេស និងអន្តរជាតិ យើងតំណាងឱ្យក្រុមហ៊ុន ចិន កូរ៉េ កាថេ ។ល។ ធ្វើលិខិត Re-Entry Permit ប្រញាប់ជូនបានទិញសំបុត្រជិះនាវាសមុទ្រ សណ្ឋាគារ ឬជួលឡាន សំបុត្រយន្តហោះទៅច្រើនប្រទេសក្នុងតម្លៃទាបបំផុត ។

Represented Several of Company such as China, Korea, Cathay etc.,
Offer Rush Re-Entry Permit
Reserve Cruise, Hotels and Car Rentals
Best Price Air Ticket for Many Destinations

600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036

ANGKOR AUTO SERVICE, INC.
ហាងជួសជុលរថយន្ត "អង្គរ"

4835 N. 16th Street.
Philadelphia, Pa 19141
Tel : (215) 455-7810
Ricky : (215) 485-1425

Specializing in Body Kit and Custom Paint
ជំនាញខាងជួសជុលតួរថយន្ត
និងបាញ់ថ្នាំដាក់ក្បាច់តាមបំណងភ្ញៀវ

RICKY
Hand Ph.: Ricky 215-485-1425

មានបទពិសោធន៍២០ ឆ្នាំ
ជាជាងរថយន្តមានសញ្ញាប័ត្រ
វាយតម្លៃការងារដោយឥតយកថ្លៃ
ហើយយើងជួយសន្សំប្រាក់តម្លៃ
បន្ថយរបស់អ៊ិនស៊ូរិន បានផង
យើងផ្តល់សេវាគ្រប់យ៉ាង :
-State inspection
-Insurance Claims
-Auto Glass Repairs
-Auto Frame Repairs
-Custom Painting
-Auto A/C






បើកពីម៉ោង ៩ ព្រឹក
ដល់ម៉ោង៥ល្ងាច ពីថ្ងៃ
ច័ន្ទ ដល់ ថ្ងៃ សៅរ៍
ចុះតម្លៃជូន 10 % បើបង្ហាញប័ណ្ណកាណិជ្ជកម្មនេះ

## ពីរដ្ឋបាលកុលសម្ព័ន្ធមករដ្ឋាភិបាលសម័យ

**ប្រែសម្រួលដោយ : ពិន សំខុន (តពីលេខមុន)**

-គេកត់សម្គាល់ថា មានប្រទេសកម្ពុជាដល់ទៅពីរ គឺ១ នៅក្នុងស្រុក រស់នៅដោយសារសហគមន៍អន្តរជាតិ ហើយទី២ នៅជំរំទល់ដែន បានទទួលការចាប់អារម្មណ៍យ៉ាងក្រាសក្រែល ។

**ឆ្នាំ ១៩៨១**

**•៨ កុម្ភៈ :** សម្តេច សីហនុ ប្រកាសថា ព្រះអង្គត្រៀមខ្លួនដើម្បីដឹកនាំចលនារួបរួមជាតិមួយដែលប្រមូលផ្តុំដោយអ្នកប្រឆាំងរបបភ្នំពេញ ។

**•២៦ មីនា :** បង្កើតហ៊្វុនស៊ិនប៉ិច FUNCIN-PEC នៅក្រុងប៉ារីស ប្រទេសបារាំង សម្តេច សីហនុ ជាព្រះប្រធាន ។

**•១ ឧសភា :** បោះឆ្នោតសភាជាតិនៅភ្នំពេញ -អាសនៈមាន១១៧-បេក្ខជនមាន១៤៨ ទាំងអស់សុទ្ធតែទទួលការយល់ព្រមពីចលនារំដោះ FUNSK ។

**•២៦-២៩ ឧសភា :** មហាសន្និបាទលើកទី៤ របស់បក្សប្រជាជន - ប៉ែន សុវណ្ណ ដែលជាអ្នកបង្ហាញសេចក្តីរាយការណ៍ជាប្រវត្តិសាស្ត្របានជាប់ឆ្នោតសារជាថ្មី ជាអគ្គលេខាបក្ស - សន្និបាទតែងតាំងគណកម្មាធិការកណ្តាល ២១ នាក់ សមាជិកការិយាល័យនយោបាយ ៨ នាក់ និងសមាជិកការិយាល័យរដ្ឋបាល ៧នាក់ ។

**•២៤ មិថុនា :** ប្រជុំពេញអង្គសភាជាតិ លើកទី១ ជា ស៊ីម ជាប្រធាន

**•២៧ មិថុនា :** សភាជាតិបានអនុម័តលើអត្ថបទរដ្ឋធម្មនុញ្ញរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ពេលនោះបានតែងតាំងប្រឹក្សារដ្ឋម្នាក់ គឺ ហេង សំរិន និងប្រធានប្រឹក្សាគណៈរដ្ឋមន្ត្រី គឺ ប៉ែន សុវណ្ណ

**•២ កក្កដា :** គណៈរដ្ឋមន្ត្រីរដ្ឋាភិបាល ប៉ែន សុវណ្ណ

**២-រដ្ឋាភិបាល ប៉ែន សុវណ្ណ (២-៧-១៩៨១-៤-១២-១៩៨១) :**

-នាយករដ្ឋមន្ត្រី : ប៉ែន សុវណ្ណ
-ប្រធានខុទ្ទកាល័យនៃក្រុមប្រឹក្សារដ្ឋមន្ត្រី : អ៊ុំង ផន
-ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីការពារជាតិ : ចាន់ ស៊ី
-ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីផែនការ : ជា សុទ្ធ
-ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីការបរទេស : ហ៊ុន សែន
-រដ្ឋមន្ត្រីមហាផ្ទៃ : ខាង សារិន
-រដ្ឋមន្ត្រីកសិកម្ម : គង់ សំអុល
-រដ្ឋមន្ត្រីឧស្សាហកម្ម : កែវ ចិន្តា
-រដ្ឋមន្ត្រីគមនាគមន៍ និងប្រៃសណីយ៍ : ឃុន ឈី
-រដ្ឋមន្ត្រីពាណិជ្ជកម្ម : តាំង សារីម
-រដ្ឋមន្ត្រីហិរញ្ញវត្ថុ : ចាន់ ភិន
-រដ្ឋមន្ត្រីកិច្ចការរដ្ឋ : ស៊ីម កា
-រដ្ឋមន្ត្រីអប់រំ : ប៉ែន ណាវុធ
-រដ្ឋមន្ត្រីសុខាភិបាល : យិត គឹមសេង
-រដ្ឋមន្ត្រីព័ត៌មាន និងវប្បធម៌ : ឆេង ផុន
-រដ្ឋមន្ត្រីយុត្តិធម៌ : អ៊ុក ប៊ុនឈឿន
-នាយកធនាគារជាតិ : ចា រៀង

(តទៅលេខក្រោយ)




## ពុទ្ធប្បវត្តិអមដោយរូបភាព

## A Pictorrial Biography of Saky amuni Buddha



❖ រូបភាព និងរឿងដើមជាភាសាថៃ ដោយ គុណាប៉ាយុតា
❖ បកប្រែជាភាសាអង់គ្លេស ដោយ ហ្សីត .អេ.លី
❖ ផាត់ពណ៌ដោយ យ៉ាន់ ហ្វាលី
❖បកប្រែជាភាសាខ្មែរដោយភិក្ខុ គង់ អាំ

❖ Original Illuatration and Naration in Thai by Gunapayuta.
❖ Translation into English by A Lu.
❖ Coloring by Yann Fang Lee
❖ Translation into Khmer by Bhikkhu Kong Am.

**៨៣-** អស់ពេលពេញមួយថ្ងៃ ព្រះអង្គទ្រង់គង់យ៉ាងស្ងៀមស្ងាត់ និងសប្បាយរីករាយក្នុងព្រៃឧទ្យានព្រះទ័យទ្រង់ដក់ជាប់តែនឹងការគិតសាងបព្វជ្ជាតែប៉ុណ្ណោះ ។ ពេលនោះស្រាប់តែមានគេទៅក្រាបបង្គំទូលថា ព្រះរាជទេពីរបស់ព្រះអង្គប្រសូត្របានបុត្រមួយព្រះអង្គគួរជាទីស្រឡាញ់ ។ ទ្រង់មិនសំដែងសេចក្តីត្រេកអរចំពោះដំណឹងនេះឡើង ព្រះអង្គទ្រង់ត្រឡប់ជាមានព្រះកង្វល់ខ្វល់ខ្វាយព្រះទ័យទៅវិញ ហើយទ្រង់មានព្រះបន្ទូលយ៉ាងសោះកក្រោះថា ចំណងនេះបានចងអញហើយតើ! ចំណងនេះបានចងអញហើយតើ! បានជាទ្រង់មានព្រះបន្ទូលដូចនេះ ដោយសារពេលនេះបុត្រទើបប្រសូត្រថ្មីមានព្រះនាមថា **រាហុល** នោះដែលមានន័យថា **ចំណង** ឬ **អន្ទាក់** ។

**83-** During that whole day, the prince sat quietly but happily in the garden, his mind captured by the idea of becoming a Sramana. Just then someone told the prince that his wife had given birth to a lovely boy. but instead of expressing his joy, the prince was a bit flusterd, and he said absentmindely: "This ring has hemmed me in!" It was because the prince spoke in this manner just at this time that the newborn baby was named Rahula, which means a ring or a circle.



**៨៤-** ចាប់តាំងពីថ្ងៃដែលរាហុលកុមារប្រសូតមក ជនទាំងឡាយដែលនៅជាប់ជាមួយព្រះសិទ្ធត្ថ បានសង្កេតឃើញយ៉ាងច្បាស់ថា ព្រះរាជឱរសទ្រង់មានការប្រែប្រួលយ៉ាងច្រើន ។ ព្រះអង្គទ្រង់មានព្រះអាការៈស្រពាប់ស្រពោន និងសញ្ជប់សញ្ជឹងខ្លាំងជាងពេលមុនៗទាំងអស់ ។ ចំណែកព្រះមហាក្សត្រសុទ្ធោទនៈវិញ ទ្រង់ព្រះវិត្តក្កៈខ្វល់ខ្វាយក្រៀមក្រំបារម្ភព្រួយក្រៃលែងចំពោះអាការៈខុសពីធម្មតារបស់ព្រះរាជបុត្រព្រះអង្គ ដូច្នេះព្រះរាជាទ្រង់ខំព្យាយាមទាក់ទាញដ៏ខ្លាំងក្លាជាចុងក្រោយ ដើម្បីដាស់អារម្មណ៍ព្រះរាជបុត្រឱ្យភ្ញាក់ទាក់ជាប់ចិត្តស្រើបស្រាលឡើងវិញ ដោយទ្រង់ជ្រើសរើសយកតែកុមារីស្រីរបាំដែលមានទេពកោសល្យប៉ិនប្រសប់ និងមានរូបឆោមស្រស់ស្អាតបំផុតក្នុងព្រះនគរឱ្យចូលមករាំច្រៀងកំដរព្រះរាជបុត្រ ។ ព្រះរាជាទ្រង់ត្រាស់ឱ្យពួកស្រីរបាំទាំងនោះស្ថិតនៅជាប់ជានិច្ចទាំងយប់ទាំងថ្ងៃក្នុងដំណាក់ព្រះរាជឱរស និងទ្រង់ត្រាស់បង្គាប់ឱ្យច្រៀងតែចម្រៀងពិរោះៗ និងរាំតាមចង្វាក់ទាក់ទាញអារម្មណ៍ឱ្យបានសប្បាយ ធ្វើដូច្នោះព្រះអង្គទ្រង់សង្ឃឹមថា វានឹងដាស់ពញ្ញាក់អារម្មណ៍ព្រះរាជបុត្រឱ្យត្រេកត្រអាលសប្បាយភ្លើតភ្លើន និងពេញព្រះទ័យចំពោះវត្ថុផ្សេងៗនាលោកិយនេះ ។

(តទៅលេខក្រោយ)

**84-** Since the day of Rahula´s birth, those who lived with Prince Siddhartha all chearly observed that the prince had changed entirely. He was more solemn than before and more contemplative. King Suddhodana was very worried indeed, about his son´s condition; and so he tried with his last effort to re-awaken his interest by searching the whole country for the interligent and beautifull dancing girls. permanetly in the prince´s palace, ordering them to sing beautifull songs and to perform pleasing dances, which, he hoped, would arouse the prince´s pleasure and interest in the thing of this world. *(Continued Issue After)*





# តមកទំព័រទី០៣ ឌុច សម្លាប់មនុស្សជាង១ម៉ឺននាក់...




សម្រាប់សាលាក្តីខ្មែរក្រហមកាត់ទោសខ្មែរក្រហមខ្ញុំគិតថា វាអយុត្តិធមិនៅតែមាន ពីព្រោះកាត់តែមនុស្ស 4-5 នាក់ហ្នឹង ។ អ៊ីចឹងខ្ញុំគិតថា វាត្រូវតែមានការពាក់ព័ន្ធផ្សេងៗទៀត សម័យ ប៉ុល ពត ពេលនោះខ្ញុំនៅតូចៗដែរ ដឹងពីការជាប់ពាក់ព័ន្ធរវាងប្រទេសជិតខាងដូចជាជាមួយយួន ជាមួយចិន មានជាប់ជំពាក់វាកិរិនគ្នានៅក្នុងសម័យខ្មែរក្រហមហ្នឹង ។ ប៉ុន្តែមិនធ្វើការចោទប្រកាន់អ្នកដែលនៅខាងក្រៅ ហើយអ្នកដែលនៅខាងក្នុងដែលជាឥស្សរជនមួយចំនួនកំពុងតែដឹកនាំរដ្ឋរាល់ថ្ងៃមើលទៅក៏មានជាប់ពាក់ព័ន្ធទៅនឹងបាតដៃប្រឡាក់ឈាមផងដែរ ។ ប៉ុន្តែទុកឱ្យមានសេរីភាព ហើយកំពុងតែធ្វើការដឹកនាំបន្តបន្ទាប់ទៀត ។ នេះវាអយុត្តិធមិមិនមានភាពស្មើគ្នាចំពោះការដែលចោទប្រកាន់វិសាលភាពនៃច្បាប់សម្រាប់កាត់ទោសខ្មែរក្រហម ។ យើងសោកស្តាយតុលាការនេះច្បាប់បានសរសេរចងថា ក្នុងចំណោមសហចៅក្រមហ្នឹង បើមានអ្នកណាមួយជំទាស់មិនអាចយកធ្វើការចោទប្រកាន់បាន គឺវាទាក់នៅត្រង់ហ្នឹង ឃើញចៅក្រមអន្តរជាតិគ្រោងនឹងចោទប្រកាន់មនុស្ស4-5នាក់ទៀត ប៉ុន្តែខាងភាគីខ្មែរយើងមិនឯកភាពត្រង់នេះយើងមើលឃើញថា វាមិនយុត្តិធមិ ។

ហើយចំណែកលោក យឹម សុវណ្ណ មន្ត្រីអ្នកនាំពាក្យមកពីគណបក្ស សម រង្ស៊ី មានការគាំទ្រដូចម្តេចដែរ ?



**យឹម សុវណ្ណ :** នេះជារឿងធម្មតាជាការសម្រេចរបស់តុលាការនេះយើងមិនធ្វើអត្ថាធិប្បាយអ្វីទេ។ ទី2 អ្នកនយោបាយទាំងអស់ត្រូវសហការជាមួយតុលាការខ្មែរក្រហមហ្នឹង ពីព្រោះតុលាការនេះជាតុលាការដែលចៅក្រមព្រះរាជអាជ្ញាអន្តរជាតិចូលរួមបើសិនជាមានការឆ្លើយបំភ្លឺបន្ថែមដោយទាមទារឱ្យមានការសហការពីអ្នកនយោបាយណាគួរណាស់ឱ្យមានការសហការជាមួយតុលាការហ្នឹងធ្វើយ៉ាងណាកាត់សេចក្តីឱ្យមានភាពយុត្តិធមិ ហើយនឹងឱ្យបានរលូនទៅមុខ ។ ហើយគ្រាន់តែថា ប្រជាពលរដ្ឋមួយចំនួនមានការខកចិត្តដែរ ពីព្រោះថា មានតែខ្មែរក្រហម4-5នាក់ហ្នឹង ទេទៅសម្លាប់មនុស្សរាប់លាននាក់នោះទេ គឺមានខ្មែរក្រហមដទៃទៀតគួរណាស់ត្រូវបានយកមកកាត់ទោស ក៏ប៉ុន្តែកំពុងតែរស់នៅដោយមានសេរីភាព មានការការពារពីអ្នកនយោបាយថែមទៀត ។

សម្រាប់លោក វណ្ណាត ដែលនៅរស់រានមានជីវិតពីគុកទួលស្លែងដ៏កម្រ និងស្ថិតក្រោមការគ្រប់គ្រងរបស់ ឌុច លោកយល់ឃើញយ៉ាងដូចម្តេចដែ ?

**វណ្ណាត :** ព្រឹកមិញនេះខ្ញុំបានចូលរួមស្តាប់នៅក្នុងការកាត់ទោស ឌុច ខ្ញុំស្តាប់ការប្រកាសជាផ្លូវការរបស់ប្រធានចៅក្រមលោករៀបរាប់អំពីតួនាទីអំពីការងារដែល ឌុច គាត់ប្រព្រឹត្តិកន្លងមកសម្រាលទោស5ឆ្នាំចំពោះខ្ញុំ ខ្ញុំឯកភាពទទួលសេចក្តីសម្រេចរបស់តុលាការពីព្រោះ ថាការប្រឹងប្រែងរបស់តុលាការក៏ចំណាយពេលយូរដែរហេតុដូច្នេះខ្ញុំសម្លឹងមើលទៅប៉ុណ្ណឹងវាយុត្តិធមិ ។

ចំណែកឯនិស្សិតឆ្នាំទី2នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ផ្នែកសារព័ត៌មានលោក ឆេង សំបូរ លោកយល់ឃើញយ៉ាងដូចម្តេចដែរ ?

**ឆេង សំបូរ :** បាទ ! តាមទស្សនៈរបស់ខ្ញុំ ខ្ញុំគិតថាតុលាការកាត់ក្តីដាក់ទោសប៉ុណ្ណឹងវាមិនសាកសម ដែលតុលាការគាត់កាត់35ឆ្នាំ ខ្ញុំក៏ដូចជាអ្នកដទៃខ្ញុំមានអារម្មណ៍មិនពេញចិត្តដែរ មិនគួរណាគាត់ធ្វើគាត់សម្លាប់មនុស្សរាប់លាននាក់ ទោះបីជាគាត់ធ្វើតាមគេបញ្ជាឬយ៉ាងណាក៏ដោយមនុស្សច្រើនបានស្លាប់ដោយសារគាត់ ។

កញ្ញា សេង ធារី ដើមបណ្តឹងជនរងគ្រោះរដ្ឋប្បវេណីនៃសំណុំរឿង001បានថ្លែងថា :

**សេង ធារី :** ចាស ! យើងឃើញថា សាលក្រមប្រកាសកាលពីព្រឹកមិញនេះជាសាលក្រមដែលយើងមិនអាចទទួលយកបាន ក្នុងនាមជាជនរងគ្រោះនៅក្នុងរបបខ្មែរក្រហម ពីព្រោះជនរងគ្រោះស្ថិតនៅក្រោមកណ្តាប់ដៃរបស់ ឌុច នៅគុកទួលស្លែង ។ អ្វីដែលបានកើតឡើងកាលពីព្រឹកមិញយើងមានភាពឆ្ងល់ យើងមានការព្រួយបារម្ភពីការជ្រៀតជ្រែកផ្នែកនយោបាយដែលអាចជះឥទ្ធិពលទៅលើសំណុំរឿង 002 ។ អ៊ីចឹងសាលក្រមកាលពីព្រឹកមិញសាលក្រមមួយដែលធ្វើឱ្យយើងមានការរន្ធត់មានភាពឆ្ងល់ មានភាពល្ងើងជូចត់នៅក្នុងការជឿថា អ្វីដែលគាត់បានធ្វើគាត់ប្រព្រឹត្តិតុលាការយុត្តិធមិបានផ្តល់ឱ្យគាត់ត្រឹមតែ19ឆ្នាំមានន័យថា ជីវិតមួយគាត់បានបង់តែ 11ម៉ោងក្នុងការទទួលធ្វើទារុណកម្មទៅនឹងភាពឃោរឃៅទៅលើភាពបាត់បង់ជីវិតមួយ ហើយយើងគុណនិង 14,000នាក់ យើងគិតមើល ។ អ៊ីចឹងអ្វីដែលកើតឡើង ជារឿងមួយហើយបារម្ភថា មានការជ្រៀតជ្រែកពីអ្នកនយោបាយធ្វើឱ្យយើងមានការអស់សង្ឃឹមទៅនឹងករណីសំណុំរឿង 002 ។



ចំពោះព្រះតេជគុណ ផាន់ សៅរ៉ា ដែលគង់នៅវត្តឧណ្ណាឡោម តើព្រះអង្គមានសង្ឃដីកាយ៉ាងដូចម្តេចដែរ?

**ផាន់ សៅរ៉ា :** ចំពោះអាត្មាផ្ទាល់35ឆ្នាំសមនឹងអាយុគាត់ ពីព្រោះឥឡូវអាយុគាត់ប្រហែលជា70ឆ្នាំ អ៊ីចឹងកាត់35ឆ្នាំល្មមត្រឹមអាយុគាត់ប៉ុណ្ណឹង ហើយនិយាយឱ្យចំទៅប៉ុណ្ណឹង គឺដូចមួយជីវិតរបស់គាត់ទៅហើយ ។

ទោះជាយ៉ាងណាក៏ដោយសហព្រះរាជ អាជ្ញាជាតិនិងអន្តរជាតិបានថ្លែងនៅក្នុងសន្និសីទកាសែតបន្ទាប់ពីប្រកាសសាលក្រមផ្តន្ទាទោសនៅថ្ងៃនេះថា ពួកគេនៅមិនទាន់ច្បាស់ថា ត្រូវប្តឹងទៅឧទ្ធរណ៍ចំពោះសេចក្តីសម្រេចនេះឬយ៉ាងណានោះទេ ។ ការប្តឹងឧទ្ធរណ៍នេះមាន30ថ្ងៃគិតចាប់ពីថ្ងៃនេះតទៅ ។ លោក កាំងហ្កិចអ៊ាវ ហៅ ឌុច ត្រូវបានបញ្ជូនមកមន្ទីរឃុំឃាំងអង្គសវនាការនៃអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី30 ខែកក្កដា ឆ្នាំ2007 ។ សវនាការកាត់ទោស ឌុច បានចាប់ផ្តើមនៅថ្ងៃទី30 ខែមីនា នឹងបានបញ្ចប់នៅថ្ងៃទី27 វិច្ឆិកា 2009 ក្នុងអំឡុងពេលសវនាការ ចំនួន77ថ្ងៃ ៕

From :Philadelphia



សួស្តីឆ្នាំថ្មី
ហាងខ្មែរជួសជុលរថយន្ត
បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ

**Rathe`s Auto Service**




State and Emission
Inspection General
Repairs and Maintenance

MON-SAT, 8:30AM -5:30PM
SUN. EMERGENCY ONLY

-ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
-មានដូរប្រេង ដូរប្រ្ញាំង ដូរកង់ និងករណីជាច្រើនទៀត ។
-មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ -មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : -ដូរប្រេងកឺរត ៥ ក្វាត $22. - INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់-មានជូនប័ណ្ណពិសេស សំរាប់ដូរប្រេង ចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
-តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត
- ប្តេជ្ញាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ ។
ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL: (215) 329-2418
Fax: (215) 329-2419.Rath CELL: (215) 431-6376

Yes you can!

... get free or low-cost health insurance for your children.

- Did you lose your health insurance when you lost your job?
- Do your children have no health insurance?
- Do you wonder how you'll afford your kids' next doctor visit?

AmeriChoice
A UnitedHealth Group Company

(215) 360-9841
Leap Thach

Your children deserve to be healthy.
AmeriChoice can help.






Think of life insurance from New York Life as a gift of financial protection. With cash value that increases every year,* even in times like these, your whole life policy can help fund a college education, pay off debts, or let you plan for the unexpected.† And what's more, it's backed by the highest possible ratings for financial strength.‡ Give your family the most selfless gift of all, a secure financial future.

NEW YORK LIFE

Concerned about your family's future? Talk to your New York Life agent today.

Pom Srey
Agent

**New York Life Insurance Company**
100 Witmer Road Suite 100
Horsham, PA 19044
(215) 441-6280
psrey@ft.newyorklife.com

THE COMPANY YOU KEEP®
www.newyorklife.com

*As premiums are paid. †The cash value in a life insurance policy is accessed through policy loans, which accrue interest at the current rate, and cash withdrawals. Loans and withdrawals will decrease the death benefit and cash value. ‡Standard & Poor's (AAA), A. M. Best (A++), Moody's (Aaa) and Fitch (AAA) for financial strength. Source: Individual Third Party Ratings Reports (as of 6/16/09). © 2009 New York Life Insurance Company, 51 Madison Avenue, New York, NY 10010

100121 AGY-1250 00398624 CV 6/11



Sav-Mor PHARMACY
Tel: 215-467-1220

ឱសថស្ថានខ្មែរ

Sav-Mor PHARMAC

Sam EA R.Ph.
2232 S. 7th St. (7th & Wolf) Philadelphia, Pa 19148
Tel: 215.467.1220 Fax: 215.467.1447



បំរើលោកអ្នកដោយមិត្តភាព និងទាន់ចិត្ត

▶▶ Sav Mor គឺជាឱសថស្ថានបំរើការចែកចាយថ្នាំ ហើយអាចពន្យល់ពីរបៀបប្រើប្រាស់ថ្នាំតាមវេជ្ជបញ្ជា ជាភាសាខ្មែរបាន យើងទទួលយកនូវ MEDICARE MEDICAID និង INSURANCES ជាច្រើនទៀតផង យើងមានលក់កាត់សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ និងអន្តរជាតិ

*Accept most insurance plans including Medicare & Medicaid
*Easy Prescription transfer
*Inside. Prepaid phone card. Call Cambodia.



# FOR SALE BY OWNER

HASS´S AUTO ជួសជុលតួឡានដែលបុគ្គលម្ចាស់ហាងចូលនិវត្តន៍-ហាងមានដំណើរការ១៧ឆ្នាំមកហើយ-ពាណិជ្ជកម្មមានលំនឹងល្អគ្រប់រដូវលោកអ្នកអាចទិញតែពាណិជ្ជកម្មក៏បាន-ទិញដីជាមួយនឹងផ្ទះក៏បាន-ទិញទាំងពីររួមគ្នាក៏បាន បើចង់ដឹងច្បាស់សូមទូរស័ព្ទរកឈ្មោះ "នីក"

Owner is retiring. 17 years in business at this location. Well established business, all seasons are busy. Option to buy only business, real estate, or both.




Contact Nick: 267-242-7938
615 W. Fisher Ave. Phila, Pa 191203



# Danny's Café




Foods & Hoagies

1. Beef Stew Serve with Bread.....................នំប៉័ងខគោ
2. Curry Chicken Serve with Bread.............នំប៉័ងការីសាច់មាន់
3. Curry Beef Saramann Serve with Bread....នំប៉័ងសាច់គោ ខការីសារាម៉ាន់
4. Meatball Soup Serve with Bread ............ស៊ុបប្រហិតជាមួយនំប៉័ង
5. Mi Siam .............................................មីសៀម





1730 Snyder Ave, Philadelphia, PA 19145 / Mon – Fri: 7am – 7pm Saturday: 9 am – 8 pm / Sunday : CLOSED
Tel: 215.467.4082 Fax: 215.467.4642 / Thank You, Please come again !



# FRANK'S TIRES




2654 S. FAIRHILL ST.
(215) 334-2261
OPE N 7 DAYS A WEEK
8 A.M. – 7 P.M.

NEW & USED TIRES
ESTBLISHED SINCE 1984


Totally Traditional!
Totally Cambodielicious!
ទាបំពងទឹកត្រីអំពិលទុំ
KAVEI CAMBODIAN RESTAURANT
Authentic Khmer • Thai • Lao • Vietnamese Phở
320 W OREGON AVENUE
(OREGON MARKET, SOUTH PHILLY)
215.952.6688
OPEN 7 DAYS A WEEK
9am-10pm